# ការធ្វើផែនការមីក្រូ

# DEVELOPING A MICRO PLAN

ដើម្បីផ្តួចផ្តើមនូវដំណើរការនៃការធ្វើផែនការ វាជាគំនិតល្អមួយដែលធ្វើឱ្យនឹកឃើញជាដំបូងនូវគំនិតរបស់អ្នកស្តីអំពីការអភិវឌ្ឍ។ អ្នកនឹងនាំទៅរកមធ្យោបាយដើម្បីបង្កើតនូវការឯកភាពសហគមន៍មួយទៅលើអ្វីដែលត្រូវអភិវឌ្ឍន៍? បើទោះជា វាមានអត្ថន័យខុសគ្នាសំរាប់មនុស្សផ្សេងៗគ្នាក៏ដោយ។ ប្រជាជនដែលរស់នៅក្នុងភូមិជាមួយគ្នា អាចមានតម្រូវការក្នុងការអភិវឌ្ឍន៍ខុសៗគ្នាដែរ ដូចជាកុលសម្ព័នភ្នំ និង dalit (តាមវណ្ណៈទាប រឺ គេកំណត់នៅក្នុងប្រទេសឥណ្ឌា) អាចចង់បានការការពារព្រៃឈើនិងដីសំរាប់ ការទ្រទ្រង់ផ្នែកចំណីអាហាររយៈពេលយូរអង្វែង ខណៈដែលក្រុមដ៏ទៃផ្សេងទៀតគាំទ្រដល់ការបង្កើតអណ្តូងស្នប់ រឺសហករណ៏ការងារដើម្បីឱ្យឆ្លើយតបទៅនឹងតម្រូវការរបស់សេដ្ឋកិច្ចភូមិ។ ការរស់របស់មនុស្សនៅក្នុងគ្រួសារតែមួយក៏មានតម្រូវការខុសគ្នាដែលត្រូវបំពេញឱ្យផងដែរ។ សំរាប់បុរសមួយចំនួនការកសាងផ្លូវគឺជាមធ្យោបាយអភិវឌ្ឍន៏ នៅពេលវាបង្កើតឱ្យមានឱកាសសេដ្ឋកិច្ចចំណែកឯ ស្ត្រីវិញអាចចង់បានឱ្យមានប្រភពទឹកនៅជិតៗផ្ទះដើម្បីសន្សំដល់ពេលវេលា ហើយកូនក្មេងអាចចង់បានសាលារៀនដែលមានគុណភាពនៅជិតផ្ទះរបស់ពួកគេផងដែរ។

នៅក្នុងការងាររបស់អ្នក អ្នកត្រូវការបង្កើតបរិយាកាសមួយដែលទស្សនះរបស់អ្នកគ្រប់គ្នា ត្រូវគេទទួលស្គាល់ថាត្រឹមត្រូវ ហើយវាបានបង្ហាញនៅក្នុងការធ្វើផែនការរបស់អ្នកផងដែរ។ រាល់ដំណើរការនៃការប្រជុំ អ្នករាល់គ្នាទាមទាការអភិវឌ្ឍមួយដែលតម្រូវឱ្យឆ្លងកាត់ការធ្វើផែនការដែលនិងបង្កើតឱ្យមានឱកាសសំរាប់គ្រប់ៗគ្នា។ ករណីនេះអាចកើតឡើងប្រសិនបើអ្នកនាំប្រជាជនឱ្យគិតជាមួយគ្នាទៅលើអ្វីជារូបភាពល្អប្រសើរសំរាប់ភូមិស្រុករបស់ពួកគេ។ តើពួកគេត្រូវធ្វើអ្វីខ្លះក្នុងកំឡុងពេល ៣ ទៅ ៥ឆ្នាំបន្ទាប់ ដើម្បីឱ្យមានការផ្លាស់ប្តូរនោះ? តើជំនួយរបស់អ្នកណាដែលពួគគេនិងត្រូវការដើម្បីទទួលបានការផ្លាស់ប្តូរដែលចង់បាន? តើពួកគេនិងធ្វើការងាររួមគ្នាដោយរបៀបណា ដើម្បីឱ្យទទួលបានគោលបំណងរួមមួយ?

មាត្រាទី ៧៣ នៃរដ្ឋធម្មនុញ្ញ បានផ្តល់សិទ្ធិអំណាចដល់ *Panchayats* (ក្រុមប្រឹក្សាភូមិ) ដើម្បីឱ្យធ្វើផែនការអភិវឌ្ឍន៏ភូមិ ដែលស្ថិតនៅក្រោមអំណាចយុត្តាធិការ និងអំណាចបែងចែកឱ្យជ្រើសរើសសមាជិក ដើម្បីរៀបចំនិងអនុវត្តន៏ផែនការអភិវឌ្ឍន៏តំបន់មូលដ្ឋាន (ហៅថាផែនការមីក្រូ) ។

ការងារមួយក្នុងចំណោមការងារដំបូងបង្អស់របស់អ្នកគឺ ធានាថាអ្នករាល់គ្នាបានយល់ដឹងពីការធ្វើសច្ចាប័នស្របច្បាប់ដែលចែងថា ធនធានរបស់ភូមិដូចជា ព្រៃឈើ ,ទឹក , ដី និង សេវាសាធារណៈ ដូចជា *anganwadi's* (មណ្ឌលថែរក្សាកុមារ) មណ្ឌលសុខភាព, អាគារ *Panchayat* ។ល។ ទាំងអស់នេះជាកម្មសិទ្ធិរួមរបស់ភូមិ។ វាគឺជាសិទ្ធិរបស់អ្នកភូមិដើម្បីឱ្យទទួលបាននិង អាចគ្រប់គ្រប់ទៅលើធនធានទាំងអស់នោះ។ ធនធានទាំងនោះគួរតែបានប្រើប្រាស់ដោយប្រសើរបំផុតតាមរយៈការត្រួតពិនិត្យការប្រើប្រាស់ពីអ្នកភូមិ។ ភាពជាម្ចាស់នៃធនធានទាំងនេះ ទាមទារឱ្យមានការចូលរួមក្នុងការរក្សាធនធានសំរាប់អ្នករាល់គ្នាប្រើប្រាស់។ នេះគឺជាអ្វីដែលយើងហៅថា ការអភិវឌ្ឍដោយមានការចូលរួម។ បញ្ញាតិនៃការអភិវឌ្ឍដោយមានការចូលរួម គឺរាប់បញ្ចូលទាំងការអភិវឌ្ឍសេដ្ឋកិច្ច និងការអភិវឌ្ឍធនធានមនុស្ស។ ប្រសិនបើ ការធ្វើផែនការប្រើនូវគោលការណ៏ទាំងឡាយនៃការអភិវឌ្ឍដោយមានការចូលរួម វានិងផ្តល់វិភាគទាននាំឆ្ពោះទៅ :

- ជួយស្រាយនូវការកសាងសមត្ថភាពរបស់ប្រជាពលរដ្ឋឱ្យចេះជួយខ្លួនឯង និងជ្រើសរើសបាននូវសមាជិកដូចដែលពួកគេត្រូវការ ព្រមទាំងផ្តល់ការគំទ្រដល់សេវាសាធារណៈទាំងឡាយដូចជាៈ អនាម័យ ផ្លូវ ធនធានទឹកស្អាត ភ្លើងអគ្គិសនី ការដឹកជញ្ជូនជាដើម ។ល។ សំរាប់ជាការធ្វើឱ្យ ប្រសើរឡើងរបស់ភូមិស្រុក។
- អភិវឌ្ឍន៏សេដ្ឋកិច្ចភូមិតាមរយៈធ្វើអោយប្រសើរឡើងនូវជីវភាពរស់នៅរបស់អ្នកភូមិ។
- បង្កើនភាពសុខដុមសង្គម និងការពេញចិត្តក្នុងចំណោមអ្នកភូមិដែលជាលទ្ធផលបានមកពីកិច្ចសហប្រតិបត្តិការ។

ការអភិវឌ្ឍដោយមានការចូលរួមតាមរយៈការធ្វើផែនការ មានឥទ្ធិពលដល់ការបែងចែកធនធាន ដល់កម្មវិធីជាក់លាក់មួយចំនួន ដែលបានធ្វើផែនការដោយឆ្លងកាត់ការឯកភាពពីសហគមន៏។

## ក. តើអ្វីទៅជា ផែនការមីក្រូ(ខ្នាតតូច)?

ផែនការសំរាប់ផ្នែកតូចបំផុតនៃកិច្ចការគ្រប់គ្រង (*Panchayat* នៅប្រទេសឥណ្ឌា) គឺ ហៅថា ផែនការមីក្រូ។ ក្នុងវិធីសាស្រ្តនេះ សមាជិក *Gram Sabha* (ជាក្រុមប្រឹក្សាភូមិ)នៃ Ward និមួយៗ ធ្វើផែនការសំរាប់សង្កាត់ផ្ទាល់ខ្លួនរបស់ពួកគេ។ ផែនការកម្រិត Ward ទាំងអស់នេះ គេអាចហៅថាជា ផែនការរបស់ប្រជាពលរដ្ឋ។ ផែនការទាំងអស់របស់ប្រជាពលរដ្ឋ ត្រូវគេដាក់បញ្ចូលគ្នាដើម្បីបង្កើតជា ផែនការកម្រិត *Panchayat* និងហៅថាជាផែនការមីក្រូ។ បញ្ហាប្រឈមមុខជាមួយអ្នកភូមិបាន ដោះស្រាយតាមរយៈដំណោះស្រាយដែលពួកគេមានអារម្មណ៏កក់ក្តៅជាមួយផងដែរ។ បញ្ហានីមួយៗបាន ដោះស្រាយនៅតាមកម្រិតមូលដ្ឋាន ដោយមានការចូលរួមរបស់សមាជិកនៃ *Gram Sabha* ពីតំណាង ដែលបានជ្រើសរើស ពីមន្រ្តីរដ្ឋាភិបាល និងពីអ្នកផ្សេងទៀត។

ផែនការមីក្រូគឺជាដំណើរការមួយដែលបង្កើតនូវការកសាងសមត្ថភាពរបស់សហគមន៏ ដើម្បី វិភាគទៅលើស្ថានភាពផ្ទាល់ខ្លួនរបស់ពួកគេ និងធ្វើការងារដើម្បីបង្កើតនូវនាគតដ៏ល្អប្រសើរមួយ។ គោលដៅ ជាទូទៅតម្រូវឱ្យឈានឱ្យដល់នូវការយល់ដឹងដែលថា អ្វីទៅជាមធ្យោបាយនៃការអភិវឌ្ឍ ហើយអ្វីជា អទិ្ធភាពចំបងសំរាប់អ្នកគ្រប់ៗគ្នា។ សេចក្តីត្រូវការសំរាប់ផែនការមីក្រូបានកើតឡើងនៅ ពេលដែលការធ្វើផែនការ ថ្នាក់កណ្តាលផ្ទេរសិទ្ធិទៅឱ្យប្រជាពលរដ្ឋមូលដ្ឋាន នូវទ្រព្យសម្បត្តិភូមិនិង ធនធានភូមិ។ នៅក្នុងផែនការនេះប្រជាជនបានប្រើប្រាស់ផ្លូវ និងអាគារផ្សេងៗ រហូតដល់ពួកគេបាន ទទួលសេវាសាធារណៈ ប៉ុន្តែពេលការជួសជុលត្រូវធ្វើឡើង ប្រជាជនមិនត្រូវបង់ខាតកំលាំងពលកម្មរឺ ធនធានសំរាប់ការជួសជុលនោះឡើយ។ ហេតុផលគឺថាពួកគេមិនបានចូលរួម និងចេញវិភាគទានក្នុង ការស្ថាបនានោះទេ។ ជាលទ្ធផលរបស់ពួកគេមិនមានអារម្មណ៏ពិនិត្យតាមដាន រឺ ទទួលខុសត្រូវដែល ឈានដល់ការ ថែរក្សានោះទេ។ ប្រសិនបើធនធាននៅក្នុងភូមិជាកម្មសិទិ្ធរបស់ភូមិឆ្លង តាមអ្នកតំណាង, ហើយការអភិវឌ្ឍរបស់វា ត្រូវគេធ្វើផែនការជាមួយប្រជាជនដែលពួកគេអាចគំទ្រនិង ការពារមិនអោយ ខូចប្រយោជន៏។

ការធ្វើផែនការសំរាប់តំបន់ជនបទតែតែងមានជាសំនួរ មុនអ្នកធ្វើផែនការចំណាយពេលវេលា ភាគច្រើនរបស់ពួកគេឱ្យក្លាយជាផ្នែកមួយនៃផែនការថ្នាក់ស្រុក/តំបន់មួយចំនួននោះ។ គ្មានការកាត់ចេញ នូវការគូសបញ្ជាក់ ដែលបានដាក់ចេញឱ្យភូមិដូចជាបំបែកអង្គភាពដែលជាជាយុទ្ធសាស្រ្តមួយចំនួនសំរាប់

តំបន់ជនបទដែលបានស្នើរឡើងនៅក្នុងផែនការទាំងនេះទេ។ ការនេះគេបានផ្លាស់ប្តូរនៅក្នុងប្រពន្ធ័ *Panchayati Raj* ។

តាមរដ្ឋធម្មនុញ្ញ ការគ្រប់គ្រងលើធនធានធម្មជាតិទាំងឡាយ មាន(ដី, ទឹក, ព្រៃឈើ,។ល។) បានផ្តល់អោយទៅ *Panchayats* និង អំណាចដែលទាក់ទងទៅនឹងការអនុវត្តកម្មវិធីអភិវឌ្ឍន៍ និង កិច្ចការគ្រប់គ្រងពឹងផ្អែកលើ *Panchayats* ផងដែរ។ ដូច្នេះ *Panchayats* គឺជាស្ថាប័នអភិវឌ្ឍន៍ នៅថ្នាក់មូលដ្ឋាន ដែលធ្វើផែនការនិង ធ្វើសំណើសុំគំរោងទាំងឡាយ។ ការងាររបស់អ្នកគឺដើម្បីចងភ្ជាប់ សមាជិក *Garm Sabha* តាមរយៈការអភិវឌ្ឍដោយមានការចូលរួមនិង ការធ្វើផែនការមីក្រូ ជាមួយ នឹងសមាជិក *Panchayat* ដែលបានជ្រើសរើស។

ដំណើរការធ្វើផែនការមីក្រូសំរួលដល់សមាជិករបស់ *Garm Sabha* ឱ្យឈានទៅដល់ការធ្វើ របៀបវារៈសកម្មភាពរបស់ពួកគេដោយភ្ជាប់រដ្ឋាភិបាល, តំណាងបានជ្រើសរើសរួច និងអ្នកដើរតួសំខាន់ៗ ដ៏ទៃផ្សេងទៀតទៅក្នុងដំណើរការនៃការអភិវឌ្ឍភូមិ។

**ផែនការមីក្រូនឹងជាប់ទាក់ទងជាមួយអ្នក:**

- រៀបចំចាត់ចែងសមាជិក *Gram Sabha* និង *Panchayats* បានឆ្លងកាត់តាមដំណាក់ការនៃការធ្វើផែនទីធនធាន ក្នុងការពង្រីកផែនទីភូមិសាស្រ្តរបស់ *Panchayat*
- វិភាគទៅលើមូលហេតុ និងផលប៉ះពាល់នៃបញ្ហាទាំងនោះ និងលើកទឹកចិត្តអ្នកគ្រប់គ្នាឱ្យគិតរកដំណោះស្រាយ
- រៀបចំផែនការ និង ថវិការជាមួយគ្នា
- វាមានការយល់ព្រមក្នុងចំណោម *Gram Sabha*
- ដាក់វាជូនទៅផ្នែកផ្សេងៗទៀត

លទ្ធផលចុងក្រោយនៃការងារធ្វើផែនការមីក្រូរបស់អ្នកនឹងបង្ហាញថាសហគមន៍ភូមិ និងធ្វើការសំរេចចិត្ត បានដោយខ្លួនឯង ថាតើការអភិវឌ្ឍប្រភេទណាដែលពួកគេចង់បាន។ ពួកគេនិងមិនពឹងផ្អែកលើរើទទួល បញ្ជារពីអ្នកក្រៅ ទៅលើអ្វីដែលគួធ្វើដើម្បីឱ្យជីវិតក្នុងភូមិប្រសើរឡើង។

## ២. តើដំណើរការធ្វើផែនការមីក្រូរបស់អ្នកនឹងមានលក្ខណៈដូចម្តេច?

ឆ្លងតាមបទពិសោធន៍របស់ *PRIA* បានបង្ហាញថា ការធ្វើផែនការមីក្រូមួយ គឺកសាងសមត្ថភាពរបស់សហគមន៍ ដើម្បីវិភាគទៅលើស្ថានភាពផ្ទាល់ខ្លួនរបស់ពួកគេ និងធ្វើការដោះស្រាយនូវបញ្ហានោះ ។ ដំណើរការនៃការធ្វើផែនការមីក្រូមួយចំនួន ត្រូវចំណាយពេល២ឆ្នាំខណៈដែលការធ្វើផែនការផ្សេងទៀតបញ្ចប់ត្រឹមតែរយៈពេល៣ខែប៉ុណ្ណោះ ។ ក្របខ័ណ្ឌការងារបានផ្តល់ឱ្យជាគំនិតដំបូងដែលនិងនាំអ្នកតាមរយៈការធ្វើដំណើរនៃការផែនការជាក់លាក់របស់ *Panchayat* របស់អ្នក ដែលនិងអាចទាញយកនូវភាពខ្លាំងរបស់វាពីការដឹកនាំក្នុងការផ្តួចផ្តើមដំណើរការនេះ ។ អំឡុងពេលនិងរយៈពេលនៃការធ្វើដំណើរការនិមួយៗដែលអ្នកនិងធ្វើគឺខុសគ្នា ដូចជាគោលដៅរួមសំរាប់ការធ្វើផែនការអនុវត្តន៏នៅសហគមន៏និមួយៗគឺខុសគ្នាផងដែរ ។

**ដំណើរការនេះមាន៣ដំណាក់កាលៈ**

- មុនធ្វើផែនការ
- ពេលកំពុងធ្វើផែនការ
- ក្រោយធ្វើផែនការ

រាល់ជំហានក្នុងដំណាក់កាលនីមួយៗ បានចង្អុលបង្ហាញអោយឃើញពីវិធីសាស្ត្រសមស្របដើម្បីធ្វើលំហាត់ពីការធ្វើផែនការមីក្រូ ។ ទោះបីជាយ៉ាងណាក៏ដោយ បទពិសោធន៏ការងាររបស់អ្នកប្លែកៗពេលអ្នកប្រើបទពិសោធន៏នោះផ្អែកលើតម្រូវការសហគមន៏របស់អ្នក និងបង្ហាញឱ្យឃើញនិងការងារត្រូវធ្វើបន្តរ ។

**គោលដៅនៃការធ្វើផែនការមីក្រូអាចដាក់បញ្ចូលដូចជាៈ**

- ការកសាងសមត្ថភាពប្រជាពលរដ្ឋឱ្យរៀបចំផែនការអភិវឌ្ឍន៏សំរាប់យកទៅអនុវត្តន៏
- ការបង្កើនមូលដ្ឋានព័ត៌មានពីតំបន់ និងអំពីប្រជាជនរបស់ខ្លួនដើម្បីប្រើប្រាស់ធនធានដែលមាន
- កំណត់ឬសគល់បញ្ហាដើម្បីដោះស្រាយ
- បង្កើតសមត្ថភាពការធ្វើសេចក្តីសម្រេចចិត្ត
- ធ្វើឱ្យប្រសើរឡើងនូវសេដ្ឋកិច្ចសង្គម និងបរិស្ថានស្របច្បាប់របស់ភូមិ

- បង្កើនសមត្ថភាពចរចារ

អ្នកអាចទទួលគោលដៅទាំងអស់ខាងលើ ដោយចល័តសមាជិកដែលបានជ្រើសរើសរួចនៅកម្រិតតំបន់និងក្រុមដែលមានស្រាប់នៅក្នុងភូមិដូចជា ក្រុមយុវជន ក្រុមស្ត្រី ក្រុមកសិករ ។ល។ ចូរចងចាំថាដើម្បីទាក់ទងឱ្យពេញលេញ និងផ្តល់ដំណឹងទៅថ្នាក់ស្រុកនិងតំបន់ឱ្យបានដឹង។ ពួកអាចជួយអ្នកឱ្យទទួលបានធនធាន នៅពេលពួកគេមានកាតព្វកិច្ចធ្វើឱ្យស្ថាប័នអភិបាលកិច្ចខ្លួនឯងនៅមូលដ្ឋានរឹងមាំជាង។

> ***ផែនការមីក្រូ គឺត្រូវស្គាល់ផងដែរថាជា:***
>
> *ការផែនការពីក្រោមឡើងលើ: ការធ្វើផែនការចាប់ផ្តើមនៅថ្នាក់ក្រោម មិនដូចដំណើការធ្វើផែនការ (ពីថ្នាក់លើចុះក្រោម)។*
>
> ***ការធ្វើផែនការដោយមានការចូលរួម:*** *ការចូលរួមរបស់សហគមន៍នៅរាល់ដំណាក់កាលនៃការធ្វើផែនការ។*
>
> ***ការធ្វើផែនការតំបន់:*** *ផ្តែកជាប់ទាក់ទងនៃការធ្វើផែនការគឺថ្នាក់ភូមិ រឺ Gram panchayat ។*

ក្នុងការពិភាក្សាដោយឯកជន ការជួបប្រជុំក្រុម និងសិក្ខាសាលា ធ្វើជាដំណាក់ៗមួយរយៈពេល អ្នកនិងសំរួលដល់សមាជិកសហគមន៏ ឱ្យប្រើប្រាស់ឧបករ-ណ៏ ធ្វើផែនការមីក្រូ ដើម្បីប្រមូលព័តិមានកម្រិតសង្កាត់និងវិភាគទិន្នន័យ ឱ្យឈានដល់ការដំណោះស្រាយបញ្ហា។ អ្នកនិងជួយប្រជាជនឱ្យរៀបចំផែនការរបស់ប្រជាជន រឺផែនការថ្នាក់សង្កាត់។ ផែនការបានកើតចេញពីដំណោះស្រាយទាំងឡាយដែលផ្តល់ឱ្យ និងទទួលយកដោយសហគមន៏ និងសំខាន់ច្រើនថែមទៀតដើម្បីពួកគេចេះទទួលខុសត្រូវលើការងារដែលធ្វើ។ ប្រជាជនម្នាក់បានសម្រេចចិត្តប្រមូលផ្តុំ លើការធ្វើផែនការការងាររបស់ពួកគេទៅលើផ្នែកជាក់លាក់នៃការងារ ខណៈផែនការរបស់ប្រជាជនក្លាយជាផែនការមីក្រូ។ ផែនការមីក្រូ គឺជាមធ្យោបាយមួយសំរាប់ការអភិវឌ្ឍសហគមន៏ភូមិទៅអនាគត។ ដំណើរការធ្វើផែនការមីក្រូរបស់អ្នក និងកសាងភាពរឹងប៉ឹងដែលមានស្រាប់របស់សង្កាត់និមួយៗ ដោយជំរុញប្រមូលផ្តុំភាពខ្លាំងរបស់ *Panchayat* ។

## គ. ដំណាក់កាលមុនពេលធ្វើផែនការ:

ការចាប់ផ្តើម កសាងបរិយាកាស និងរៀបចំសិក្ខាសាលាតំរង់ទិស ដើម្បីផ្តល់យល់ដឹងជាទូទៅលើការធ្វើផែនការមីក្រូ។

### ***ជំហានទី១: កំនត់អត្តសញ្ញាណរបស់*** *Panchayat*

ការជ្រើសរើស *Panchayat* អាចពឹងផ្អែកលើកត្តាជាច្រើនដូចជា ទីតាំង(ភូមិនៅម្ខាងផ្លូវរឺវាស្ថិតនៅឆ្ងាយពីផ្លូវធំពេក) កំណត់បញ្ហា (ជះឥទ្ធិពលដោយគ្រោះរាំងស្ងួត រឺទឹកជំនន់ រឺការប្រឈមនឹងបញ្ហាដែលកើតឡើងជាទៀងទាត់) និងការដឹកនាំ (ដឹកនាំដោយអ្នកដឹកនាំស្វាហាប់រឺ មានភាពជាអ្នកដឹកនាំមានឥទ្ធិពល)។

បន្ទាប់ពីធ្វើការសំរេចចិត្តលើ *Panchayat* ថាតើអ្នកនឹងធ្វើកិច្ចការនេះនៅឯណា អ្នកចង់បង្កើតឱ្យមានបរិយាកាសមួយជាកន្លែងដែលមនុស្សសំខាន់ៗនិងចូលរួមស្តាប់អ្នក ហើយទទួលយកគំនិតអ្នកដាក់ចូលក្នុងការអភិវឌ្ឍភូមិ។ វាជាគំនិតដ៏ល្អមួយដែលត្រូវហៅអ្នកដែលសំខាន់ៗនៅក្នុង *Panchayat* ឱ្យធ្វើផែនការ និងណែនាំពីការធ្វើផែនការមីក្រូ។ វាចាំបាច់ដែលត្រូវដឹងពីការពង្រីកទីតាំងភូមិសាស្ត្រនៃ *Panchayat* របស់អ្នក ដូចជាបំបែកទិន្នន័យរបស់ចំនួនប្រជាជន និងធនធាននៅតំបន់នោះជាដើម។ ព័ត៌មានដំបូង (*Primary information*) អាចគេប្រមូលចេញពីសហគមន៍។ អ្នកអាចប្រើឧបករណ៍ *Transcent Walk* រឺ *Timeline* (ពន្យល់ពេលក្រោយ)ដើម្បីកសាងទំនាក់ទំនងពេលប្រមូលព័ត៌មានតាមការណែនាំ។ ព័ត៌មានមួយចំនួននិងអាចរកបាននៅតាមការិយាល័យ។ អ្នកអាចទទួលបានព័ត៌មានពីទិន្នន័យជាផ្លូវការផងដែរ ដូចជាបានពីជំរឿន និងរបាយការណ៍ផ្សេងៗទៀត។ ដើម្បីឱ្យដឹងពីផលិតភាពរបស់ភូមិដែលរាប់បញ្ចូលទាំង ការងារចំបង អត្រាប្រាក់បៀវត្សរ៍ និងទិន្នផលអាហារ និងប្រភពផ្សេងទៀតដែលផ្អែកលើ *Panchayat*។ អ្នកអាចចាប់ផ្តើមដោយរៀបចំនូវកម្មវិធីតំរង់ទិសមួយសំរាប់សមាជិក *Panchayat* ដែលបានជ្រើសរើសរួច ទៅតាមតួនាទីរបស់ពួកគេនៅក្នុងការធ្វើផែនការមីក្រូ។

***ជំហានទី២: ធ្វើការជាមួយអ្នកតំណាងដែលបានជ្រើសរើសរួចដែលត្រូវដាក់បញ្ចូល រឺត្រូវដកចេញ:***

អ្នកគួរធ្វើការអញ្ជើញអ្នកចូលរួម អ្នកមិនមែនតំណាង រឺអ្នកតំណាង ដើម្បីធានាថាគ្រប់សង្កាត់និងគ្រប់ផ្នែកទាំងអស់បានឱ្យចូលរួម ដូចជា ស្ត្រី កូនក្មេង មនុស្សចាស់ ជនពិការ ជនជាតិភាគតិចកុលសម្ព័ន្ធភ្នំ ។ល។ បើចាំបាច់គួរបំបែកការជួបជុំតាមអ្នកដឹកនាំសង្កាត់ខុសៗគ្នា អ្នកតំណាងឱ្យស្ត្រី តំណាងកុមារ និងតំណាងរដ្ឋាភិបាល។

***ជំហានទី៣: សិក្ខាសាលាស្តីពីការតំរង់ទិស***

គោលដៅចំបងរបស់សិក្ខាសាលានេះគឺដើម្បីបង្កើតអោយមាននូវការយល់ដឹងជាទូទៅមួយស្តីអំពីការធ្វើ ផែនការមីក្រូសំរាប់សំរាប់មនុស្សសំខាន់ៗ។ ខណៈពេលដែលរៀបចំសិក្ខាសាលាតំរង់ទិសនេះ នាំឱ្យដឹងថា អ្នកបានជួបជាមួយមនុស្សដែលគេដកចេញ នៅពេលដែលអ្នកទាំងនោះជាមនុស្សដែលមានឥទ្ធិពល។ អ្នកគួរតែអញ្ជើញអ្នកដែលមានមុខងារនៅក្នុងរដ្ឋាភិបាលនៅថ្នាក់មូលដ្ឋានឱ្យចូលរួមផងដែរ។ គួរយកចិត្តទុកដាក់ចំពោះមនុស្សដែលមិន ប្រកាន់ប្រពៃណីដែលជាអ្នកមានឥទ្ធិពល។ អ្នកត្រូវអញ្ជើញមន្ត្រីមុខងាររបស់រដ្ឋាភិបាលថ្នាក់តំបន់។ *Block Department Office* គួរតែគេផ្តល់ដំណឹងឱ្យដឹងពីដំណើរការផែនការមីក្រូ និង *Block Department Office* គួតែគេអញ្ជើញឱ្យចូលរួមផងដែរ។ លិខិតអញ្ជើញត្រូវផ្ញើរចេញឱ្យច្រើនជាមុនពេលនោះជាទូទៅមន្ត្រីរដ្ឋាភិបាលក៏ត្រូវគេអញ្ជើញផងដែរ។ កិច្ចប្រជុំទាំងនោះនិងរៀបចំឡើងសំរាប់ប្រជាជនដែលបានចូលរួមដើម្បីកំណត់ធនធានទាំងឡាយ និងពីពេលវេលាផងដែរបើចាំបាច់។ ឥឡូវនេះតាមរយៈដំណើរការដែលឆ្ពោះទៅរកការរក្សាការញ្ជើញ និងការជូនដំណឹងដល់មន្ត្រីរដ្ឋាភិបាលមូលដ្ឋាន ធ្វើទៅតាមដំណើរការ/ជំហានខុសៗគ្នារបស់ផែនការមីក្រូ។ សិក្ខាសាលាតំរង់ទិសនេះនឹងគ្របដណ្តប់ដោយសង្ខេបដូចខាងក្រោមៈ

- ភាពខុសគ្នារវាងការធ្វើផែនការតាមបែបមជ្ឈការនិង ការធ្វើផែនការតាមបែបវិមជ្ឈការ
- ហេតុអ្វីបានជាដំណើរការធ្វើផែនការមីក្រូមានសារៈប្រយោជន៏សំរាប់ភូមិ ?
- តើអ្វីខ្លះជាដំណើរការនិងជំហាននៃការធ្វើផែនការមីក្រូ ?
- តួនាទីរបស់ *gram sabha* និងសមាជិកដែលបានជ្រើសរើសរួច
- តួនាទីនិងទំនាក់ទំនងរបស់សហគមន៏ខុសៗគ្នាក្នុងភូមិ
- តើត្រូវការព័តិមាននិងធនធានអ្វីខ្លះបន្ថែមទៀត ?
- តើប្រភពមូលនិធរបស់ *Panchayat* បានមកពីអ្វីខ្លះ ?
- ការពិភាក្សាឆ្ពោះបន្តរទៅមុខទៀត
- ការធ្វើផែនការសំរាប់ប្រជាជនៈ តើអ្នកណានិងធ្វើអ្វី នៅពេលណា សំរាប់ការធ្វើផែនការកម្រិតសង្កាត់ ?

គណៈកម្មការគ្រប់គ្រងក្រុមមួយអាចគេជ្រើសរើសឱ្យធ្វើការងារពីពេលនេះតទៅៈ

## ឃ. ដំណាក់កាលធ្វើផែនការ:

### ជំហានទី៤: កំណត់បញ្ហានិងដំណោះស្រាយ

អ្នកនឹងធ្វើការជាមួយសមាជិកក្រុមគណៈកម្មការដែលទទួលខុសត្រូវប្រមូលផ្តល់ពត៌មានដូចខាងក្រោម សំរាប់សង្កាត់និមួយៗ ដោយមានជំនួយពីគណៈកម្មការ។

| បញ្ហា | បញ្ហាជាអាទិភាព | មូលហេតុ | ដំណោះស្រាយសំរាប់បញ្ហានិមួយៗ |
|---|---|---|---|
| | | | |
| | | | |

មានតម្រូវការធ្វើអទិភាពនៃបញ្ហាហើយបន្ទាប់មកជ្រើសរើសយកបញ្ហាមួយរឺពីរនៅក្នុងសង្កាត់និមួយៗ ដើម្បីផ្តោយការយកចិត្តទុកដាក់លើបញ្ជីរដំណោះស្រាយ សំរាប់បញ្ហាជាក់លាក់មួយៗ។ គណៈកម្មការគ្រប់គ្រងសំរួលការងារប្រជាពលរដ្ឋលើការដោះស្រាយបញ្ហា ជាជាងជាប់ទាក់ទងនៅនឹងបញ្ហា។ គណៈកម្មការគ្រប់គ្រងនិងត្រូវបន្ថែមលទ្ធផលព័ត៌មាន បច្ចេកទេស សេដ្ឋកិច្ច ផ្តល់ដោយការគូសបញ្ជាក់ជាវិជ្ជមាននៃព័ត៌មានទាំងអស់ដែលពាក់ព័ន្ធដើម្បីដាក់បញ្ចូលនៅក្នុងផែនការមីក្រូ។

### ការប្រមូលពត៌មាននឹងទិន្នន័យ:

នៅក្នុងជំហាននេះអ្នកនឹងធ្វើកិច្ចប្រជុំជាមួយគ្រប់សង្កាត់ទាំងអស់របស់ Panchayats ដាច់ដោយឡែកៗ ដើម្បីឱ្យទទួលបានតាមរយៈការដោះស្រាយបញ្ហារបស់សហគមន៏។ គោលបំណងនៃកិច្ចប្រជុំនេះគឺដើម្បី រៀបចំក្រុមប្រមូលព័ត៌មាន ដូច្នេះផែនការរបស់អ្នកកាន់តែរឹងមាំដោយមានភាពពិតជាក់ស្តែងផងដែរ។ ចំពោះឧបករណ៏សំរាប់ធ្វើកិច្ចការនេះនឹងលើកមកពន្យល់នៅពេលក្រោយ។ ដំណើរការប្រមូលព័ត៌មាន ដឹកនាំក្រុមប្រជាជនផ្សេងៗគ្នា ឱ្យកាន់តែស្និទ្ធស្នាលគ្នាទៅវិញទៅមក ហើយយល់ដឹងពីធនធានទាំងឡាយដែលត្រូវថែរក្សា ប្រើប្រាស់ ចែករំលែក និងដាក់បញ្ចូលគ្នា។

ប្រភេទនៃព័ត៌មានដែលអ្នកត្រូវប្រមូលរួមមាន:

- តើ Panchayats មានអ្វីខ្លះ: ធនធានធម្មជាតិ-ទឹក (ផ្ទៃខាងលើនិងខាងក្រោម) ព្រៃឈើ ដី ធនធានមនុស្ស: (អាយុ ភេទ កំរិតការអប់រំ សុខភាព ស្ថានភាពសេដ្ឋកិច្ច)។

- តើប្រើប្រាស់ធនធានយ៉ាងដូចម្តេចៈ សេវាចិញ្ចឹមជីវិត (ការងារនឹងមិនមាន ការងារធ្វើ) សេវាសាធារណៈ សាលារៀន មណ្ឌលសុខភាព Panchayat ghar (អាគាជួបប្រជុំរបស់ភូមិ) ផ្លូវថ្នល់ ផ្ទះសំបែង ស្រែចំការ។
- ពតិមានទ្រព្យសម្បត្តិៈ (សាធារណៈនឹងឯកជន) ដូចជា សត្វចញ្ចឹម ម៉ាស៊ីន ។ល។
- ពតិមានកសិកម្មៈ តំរូវការដីធ្លីនិងកម្លាំងពលកម្ម។
- ពតិមានពីការបង្កើតក្រុមសង្គម
- ពតិមានស្តីពីផែនការអភិវឌ្ឍន៏ភូមពីអតីតកាល(វិភាគទានរបស់រដ្ឋាភិបាលនឹងវិភគទានរបស់សហគមន៏) ពតិមានធនធានភូមិខ្លះទៀតអាចជាពតិមានទូទៅហើយពតិមានខ្លះទៀតអាចជាពតិមាន ជាក់លាក់ដែលសហគមន៏ត្រូវការបង្ហាញ។

អ្នកប្រហែលជាត្រូវការពតិមានដែលមានគោលបំណងច្បាស់លាស់ ដូចជាប្រើប្រាស់សំរាប់ពេលរាំងស្ងួត ដើម្បីបង្កើតជាចនាសម្ព័ន្ធគ្រប់គ្រងទឹក ដូចជា anicuts ទំនប់ត្រួតពិនិត្យនិងភ្ជាប់ Panchayat ជាមួយគំរោងការជីកអណ្តូងទឹក ហើយប្រហែលជាកិច្ចការនេះ អាចធ្វើការកត់ត្រាពីការផ្លាស់ប្តូរនិងធនធានដែលបានមកពីភូមិ វានិងផ្តល់នូវសារៈសំខាន់ឱ្យដឹងនូវអ្វីដែល គំរោងកំពុងមានព្រមទាំងផែនការអភិវឌ្ឍន៏ដែលកំពុងដំណើរការ រឺដើម្បីទទួលបានការយល់ព្រមរួចរាល់ពី panchayat ដែលជ្រើសរើសរួច ហើយបែងចែកអ្វីដែលបានធ្វើរួចរាល់ហើយដែលស្ថិតនៅក្រោមផែនការអភិវឌ្ឍន៏តំបន់ ដូចជាផែនការសុខភាព គំរោងសុខមាលភាពស្ត្រីនិងកុមារ ។ល។

***ជំហានទី៥ៈ តំរៀបលំដាប់មិន្នន័យរបស់ Panchayat:***

ព័ត៏មានក៏រិតសង្កាត់អាចប្រមូលតាមរបៀបតាមវិស័យ។ ដូចជា វិស័យសុខភាព អនាម័យ រឺទាំងផ្នែកអប់រំ ហើយព័ត៏មានទាំងនេះអាចបំពេញបន្ថែមដោយព័ត៏មានពីក្រុមមនុស្ស (ស្ថានភាពស្ត្រីកសិករ កម្មករ កូនក្មេង ។ល។) រឺប្រវត្តិការងានិងការអប់រំរបស់ភូមិ។

## ខ. កំណត់ដំណោះស្រាយគន្លឹះ

| លេខWard | បញ្ហាWard | ដំណោះស្រាយបញ្ហា | នណាជាមនុស្សដែលមានឥទ្ធិពល | នណាជាមនុស្សដែលមានឥទ្ធិពលបំផុត ហើយដោយរបៀបណា | តើគ្រួសារលេខប៉ុន្មានរឺជាមនុស្សដែលទទួលបានផលប្រយោជន៏ពីដំណោះស្រាយនេះ |
|---|---|---|---|---|---|
| | | | | | |

សម្រាប់បញ្ហានីមួយៗ ដែលសមាគមស្នើឡើងឱ្យដោះស្រាយ ការដោះស្រាយនឹងបង្ហាញបន្ថែមទៅលើព័តិមានអ្វីដែលត្រូវប្រមូលសម្រាប់ព័តិមានបន្ទាប់ទៀត ដូចជាធ្វើបញ្ចប់ផែនការ Micro នៅពេលដែលដំណោះស្រាយនេះជាដំណាក់កាលចាំបាច់ សម្រាប់បង្កើតផែនការ Micro អ្នកអាចជ្រើសរើសសកម្មភាពក្នុងក្រុមខុសគ្នា ដើម្បីបញ្ជាក់ទៅលើផ្នែកនីមួយៗ ហើយក៏ចូលរួមដោយបំបែកជា Gender និងការបង្កើតក្រុមសម្រាប់វិភាគព័តិមានផងដែរហើយកំណត់នូវអាទិភាពដែលត្រូវអភិវឌ្ឍនិងដោះស្រាយ ។

ព័តិមានពីសង្កាត់នីមួយៗគួរតែបញ្ចូលទៅលើមូលដ្ឋានស្រដៀងគ្នានិងខុសៗគ្នានៅពេលបន្ទាប់ ។ ព័តិមានទាំងនេះ គួរធ្វើជាបញ្ជីដាច់ដោយឡែក ដែលព័តិមាននីមួយៗអាចទទួលស្គាល់អំឡុងពេលធ្វើបញ្ជីអាទិភាពព័តិមាន ។ ព័តិមានដែលប្រមូលបានសម្រាប់គោលបំណង់វិភាគ ។ ខណៈដែលធ្វើលំដាប់ទិន្នន័យអំពីបញ្ហា ទាំងឡាយនោះ គេអាចរកឃើញឬសគល់មូលហេតុដើម្បីផ្តោតលើដំណោះស្រាយដែលត្រឹមត្រូវ ។ ដំណោះស្រាយតាមរយៈ Tree Diagram អាចប្រើសម្រាប់ដោះស្រាយបញ្ហាទាំងនោះ ។ ព័តិមានពីសង្កាត់មួយ អាចចែករំលែកនៅក្នុងកិច្ចប្រជុំកម្រិតសង្កាត់នីមួយៗ ដើម្បីឈានទៅដល់ការវិភាគជាទូទៅមួយ អំពីភាពរឹងមាំនៃការប្រមូលព័តិមាននិងគម្លាតនៃសង្កាត់ដូច ដែលគម្រោងអភិវឌ្ឍន៏ ដែលផ្តល់ទិន្នន័យដោយ Based Line Data ។

## ច. ការចែងចែកព័តិមានដែលប្រមូលបាននៅក្នុងកិច្ចប្រជុំថ្នាក់Ward

- កោះប្រជុំនៅពេលដែលព័តិប្រមូលរួច

- ធ្វើជាតារាង នូវទិន្នន័យដែលចង់បានរបស Ward ដែលធ្វើដោយក្រុមប្រជាពលរដ្ឋតូចៗ ប៉ុន្តែវាចាំបាច់ក្នុងការបែងចែកនូវលទ្ធផលទាំងអស់ជាមួយនឹងសហគមភ្លាមៗនៅក្នុងកិច្ចប្រជុំក្រុមធំ ។
- ការផ្តោតរបស់កិច្ចប្រជុំក្រុមធំ មិនត្រូវបង្កើតការព្រមព្រៀងរួមមួយស្តីអំពីស្ថានភាពសេដ្ឋកិច្ចសង្គមរបស់ភូមិទាំងមូល និងបញ្ហាដែលត្រូវគេលើកឡើង ។

***ជំហានទី៦: បញ្ចប់ផែនការមីក្រូ:*** បន្ទាប់ពីទិន្នន័យបានប្រមូលរួចដំណើរការនៃការដាក់បញ្ចូលផែនការប្រជាជនទៅក្នុងផែនការមីក្រូសម្រាប់ Panchayat អាធ្វើឡើង ។ គណៈកម្មការគ្រប់គ្រងគួរតែអញ្ជើញ សមាជិកសមាគមសំខាន់ៗ និងមន្ត្រីរដ្ឋាភិបាលដូចជា Block Development Office និងមន្ត្រីអប់រំស្រុកដែលពាក់ព័ន្ធ មន្ត្រីសុខភាពដែលពាក់ព័ន្ធ ឬក៏មន្ត្រី កសិកម្មដែលពាក់ព័ន្ធ ឱ្យចូលរួមប្រជុំដើម្បីចែករំលែកព័ត៌មាន ជាលក្ខណៈគុណភាពនិងបរិមាណហើយកិច្ចប្រជុំនេះអាចធ្វើដោយតំណាងស្រុក ដែលបង្ហាញនូវការវិភាគទិន្នន័យរបស់ពួកគេ ។

រៀបចំកិច្ចប្រជុំកម្រិត Panchayat មួយដោយផ្តោតលើចំណុចមួយចំនួនដូចខាងក្រោម :

**ពិនិត្យមើលដំណោះស្រាយបញ្ហាដែលបានកំណត់ឡើងវិញ :** នៅក្នុងជំហានដំបូងបំផុតនៃដំណើរការនេះ អ្នកបានរាយបញ្ហារួចហើយ តាមកម្រិតផ្សេងៗគ្នា ដើម្បីធ្វើឱ្យប្រជាជនដឹងថាបញ្ហាមួយចំនួនអាចដោះស្រាយជាលក្ខណៈបុគ្គលបាន បញ្ហាផ្សេងទៀតអាចដោះស្រាយតាមរយៈជំនួយរបស់អ្នកជិតខាងរបស់យើង ហើយបញ្ហាមួយចំនួនទៀតអាចប្រមូលផ្តុំដើម្បីដោះស្រាយតាមរយៈ Panchayat វានឹងធ្វើទៅបានល្អដើម្បីចងចាំនូវអ្វីដែលយើងបានធ្វើរហូតមកដល់ពេលនេះ ដូច្នេះ ប្រជាជនរបស់អ្នកអាចធ្វើផែនការឆ្ពោះទៅមុខបាន ។

**ធ្វើអាទិភាពនៃដំណោះស្រាយ:** នៅពេលដែលធនធានទាំងឡាយបានកំណត់ដំណោះស្រាយទាំងអស់មិនអាចធ្វើរួមគ្នាបានទេទោះបីជាយ៉ាងណាក៏ដោយក៏ដំណោះស្រាយជាគន្លឹះត្រូវតែកំណត់ឡើង ។ វិធីសាស្ត្រទាំងឡាយបានប្រើប្រាស់: Wealth Ranking Checklist អាចប្រើនៅដំណាក់កាលនេះដើម្បីរកឱ្យឃើញនូវបញ្ហាជាអទិ្ទភាព ។

**បញ្ជាក់នូវដំណោះស្រាយនិងយុទ្ធសាស្ត្រ:** ផ្អែកលើមូលដ្ឋានទិន្នន័យនៃការធ្វើ PRA លើកដំបូងដែលបញ្ហាទាំងឡាយគេបានកំណត់ជាអទិ្ទភាពសំរាប់ធ្វើការដោះស្រាយនិងសំរាប់ធ្វើជាយុទ្ធសាស្ត្រ ។

**ការកំណត់ទីតាំងធនធានៈ** បើទោះបីជាគ្មានការរុករកធនធានជាលក្ខណៈជំនាញវិជ្ជាជីវៈក៏ដោយ ក៏គេអាចប្រមូលព័ត៌មានបានដែរនៅពេលដែលយើងយល់ច្បាស់ពីរបៀបធ្វើផែនការមីក្រូ របស់ពួកយើង ដែលដឹងតម្រូវឱ្យធ្វើហើយយើងក៏អាចសុំជំនួយផងដែរ ។

ឥឡូវនេះ ដំណើរដែលបានបង្កើតជាក្រុមសាមគ្គីប្រជាជនឱ្យធ្វើការទៅលើការកសាងឆន្ទៈនយោបាយ ។ ឆន្ទៈធ្វើគោលនយោបាយរបស់ប្រជាជនគឺជាអំណាចដូចជាអំណាចរបស់ MLA និងអំណាចរបស់ MP's គឺតម្រូវ ឱ្យធានានូវធនធានហិរញ្ញវត្ថុ និងធនធានមនុស្សសម្រាប់ផែនការមីក្រូ ទោះបីជាយ៉ាងណា ក៏ដោយពួកគេគួរតែ អាចសម្រេចបាន ។

## ឆ. ដំណាក់កាលក្រោយធ្វើគម្រោងអនុវត្តន៍និងពិនិត្យតាមដាន :

អនុវត្តនិងពិនិត្យតាមដាន :

***ជំហានទី៧: សម្រេចចិត្តជ្រើសរើសរបៀបគ្រប់គ្រងក្នុងការអនុវត្តផែនការមីក្រូ :*** ទោះបីយ៉ាងណាក៏ដោយ ការធ្វើផែនការការងារគឺជាការ ទទួលខុសត្រូវរបស់មនុស្សម្នាក់ដើម្បីចាត់ចែងនិងអនុវត្តដំណាក់កាលនេះ អ្នកត្រូវបន្តទំនាក់ទំនងល្អ ជាមួយនឹងមនុស្សសំខាន់ៗ នៅក្នុងដំនាក់កាលនេះផងដែរ ។ ការចូលរួមដ៏សកម្មរបស់គណៈកម្មការភូមិ ក្រុមស្ត្រី ក្រុមកុមារ ហើយនិងក្រុមផ្សេងទៀតអាចជួយអ្នកនៅក្នុងដំណាក់កាលនេះផងដែរ ។

## ជ. ទទួលយល់ព្រមអនុវត្តកិច្ចការតាមរបៀបជាវដ្ត-ការទទួលខុសត្រូវផ្ទាល់ខ្លួន :

នៅក្នុងកិច្ចប្រជុំមួយ អ្នកអាចធ្វើផែនការថាអ្នកណានឹងធ្វើអ្វីខ្លះ? បញ្ចប់នៅពេលណា? ដែលអាចចុះជាបញ្ជី ។ កិច្ចការនេះ គួរតែធ្វើតាមផ្អែកទៅលើការគាំទ្រដែលត្រូវការ ។ គណៈកម្មការគ្រប់គ្រង ធ្វើការត្រួតពិនិត្យទៅលើការទទួលខុសត្រូវទាំងនេះ ។ ការងារត្រួតពិនិត្យនេះ អាចធ្វើឡើងនៅពេលកិច្ចប្រជុំ ដើម្បីទទួលស្គាល់នូវលទ្ធផលរំពឹងទុកពីការធ្វើផែនការ ។ កិច្ចប្រជុំនេះនឹងនាំឱ្យប្រជាជនដឹងនូវអ្វីដែលត្រូវស្វែងរកនៅពេលពិនិត្យតាមដាននិងវាយតម្លៃ ។

## ជំហានទី៨: ការត្រួតពិនិត្យ និងតាមដាន

អ្នកនឹងត្រូវរក្សាស្ថានភាពឱ្យរស់រវើក ដោយកោះហៅឱ្យមានការប្រជុំ ដើម្បីត្រួតពិនិត្យផែនការមីក្រូ វាប្រសើរបំផុតដែលត្រូវបង្កើតការកំណត់ពេលវេលាសម្រាប់កិច្ចប្រជុំតាមពេលកំណត់ :

- ស្នើរគណៈកម្មការគ្រប់គ្រងឱ្យដឹកនាំការប្រជុំដើម្បីត្រួតពិនិត្យផែនការសកម្មភាព
- ពិនិត្យឡើងវិញនូវទិសដៅនិងគោលដៅគម្រោងរបស់អ្នក
- អនុវត្តតាមផែនការមីក្រូដើម្បីរកឱ្យឃើញនូវអ្វីដែលបានកើតឡើងនៅពេលផែនការបានអនុវត្តនិងអ្វីដែលជាប់ទាក់ទង នៅពេលអនុវត្តកិច្ចការតាមវដ្ត ។
- ត្រួតពិនិត្យឡើងវិញនូវអ្វីដែលអ្នកធ្វើបានតិច ធ្វើបានច្រើន ខុសគ្នា
- ចែករំលែកចំណេះដឹងជាសាធារណៈនៃសហគមន៍ និងអ្នកដទៃទៀត
- ប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយ ដើម្បីផ្សព្វផ្សាយការអនុវត្តដែលល្អៗ

## ឈ. ឧបករណ៍សម្រាប់ធ្វើផែនការមីក្រូ

អ្នកអាចប្រើប្រាស់នូវឧបករណ៍តាមបែបចូលរួមមួយចំនួនរបស់វិទ្យាស្ថាន PRIA និងដៃគូរបស់វាដែល បានប្រើដើម្បីអនុវត្តការធ្វើផែនការមីក្រូ ។ ឧបករណ៍ខ្លះទាក់ទងទៅនឹងការប្រមូលផ្តុំព័ត៌មានខណៈពេលដែល ឧបករណ៍ដទៃទៀតអាចជួយបង្កើតនូវការប្រមូលផ្តុំការយល់ដឹង ។ បញ្ជីឧបករណ៍នេះគឺបានដាក់បង្ហាញ ហើយអាច ប្រើជាជំហានៗទៅតាមតម្រូវការនៃបរិបទ និងបញ្ហានីមួយៗ ។

### ជំហានទី១

Transect Walk
Time line

### ជំហានទី២

Relationship matrix
Social Mapping

### ជំហានទី៣

Stakeholder analysis
Resource Mapping
Service Mapping

## ជំហានទី ៤ និង ៥

ការវិភាគបញ្ហានិងស្វែងរកដំណោះស្រាយតាមរយៈដ្យាក្រាមដើមឈើ tree diagram

## ជំហានទី៦

Trand analysis
Sector wise planning

## ជំហានទី៧ និង ៨

Large Group Discussion
Focused Group Discussion

ការប្រើប្រាស់ឧបករណ៍ទាំងឡាយនោះដោយរឹងត្អឹងមិនអាចបត់បែនបាន អាចមានគ្រោះថ្នាក់ ។ អ្នក ត្រូវចាំថាការធ្វើផែនការមីក្រូ គឺជាដំណើរការផ្តល់សិទ្ធិអំណាចឱ្យប្រជាជនឱ្យធ្វើជាម្ចាស់លើ ធនធានក្នុងភូមិ និងធ្វើផែនការដើម្បីការលូតលាស់ប្រកបដោយចេរភាព។ ដូច្នេះកិច្ចការនេះជាធ្វើជាចំណុចកណ្តាល ដែលអ្នកនាំអ្នក ឱ្យឃ្លាតចេញឆ្ងាយពីដំណើរការស្មុលនៃការបង្កើតឱ្យមានភាពម្ចាស់ការលើដំណើរការទាំងអស់និងស៊ីសង្វាក់គ្នា នៅក្នុងការងារ។ នៅពេលដែលអ្នកជាអ្នកផ្តួចផ្តើមគំនិតនៃដំណើរការនេះ អ្នកត្រូវឆ្លើយតបទៅនឹងការផ្លាស់ប្តូរស្ថានភាពនៅពេលធ្វើដំណើរការធ្វើផែនការនិងការអនុវត្តផែនការ។